# គម្រោងបន្ទាញបច្ចេកវិទ្យាដើម្បី បង្កើនផលិតភាព ជុំវិញតំបន់ទន្លេសាប

TSTD (ADB TA 7305-CAM)

## បច្ចេកទេសចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ






ខែវិច្ឆិកា ឆ្នាំ២០១១

## សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រុក បានផ្តល់នូវចំណូលបន្ថែមជាប្រចាំខែដល់គ្រួសារ ដោយចំណាយពេលទំនេរ និង ធនធានមួយចំនួនប៉ុណ្ណោះ។ ទន្ទឹមនឹងការចិញ្ចឹមនេះ កសិករនៅតែអាចប្រកបរបរ ឬការងារផ្សេងទៀតបាន។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមមាន់មេ និងបា ២១ក្បាល (មេ ១៨ និង បា ៣) អាចទទួលផលពីការលក់មាន់ចំនួន ៥០គីឡូ ក្នុង១ខែៗ ហើយបានចំណូលសរុបជាមធ្យម ៨០ ម៉ឺនរៀល ។ កសិករអាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ពី ៣០ ទៅ ៣៥ ម៉ឺនរៀល ក្នុង ១ខែៗ ។ ប្រាក់ចំណូលនេះ នឹងកើនឡើងបន្ថែមទៀត បើ កសិករបង្កើនចំនួនមេបាមាន់ ។ តាមបច្ចេកទេសចិញ្ចឹមថ្មីនេះ មេមាន់ ១ក្បាល អាចផលិតកូនបានពី ៦ ទៅ ៧សំបុក ក្នុង ១ឆ្នាំ ហើយកូនមាន់មិនងាប់ ចិញ្ចឹមបានរស់ដល់ធំ ក្នុងរយៈពេលតែ ១០៥ថ្ងៃ ដែលមានទម្ងន់ជាមធ្យម ១,២ គីឡូក្រាម ក្នុង ១ ក្បាល ។

## តើធ្វើដូចម្តេចដើម្បីឲ្យការចិញ្ចឹមមាន់ទទួលបានជោគជ័យ ?

### ១. ការរៀបចំទ្រុងសម្រាប់ចិញ្ចឹម

#### ក. ទ្រុងមេបា និងមាន់បំប៉នសាច់សម្រាប់លក់

- សាងសង់ទ្រុងមាន់លើដី មិនលិចទឹក
- តួរោងមានបណ្តោយ ១០ម និងទទឹង ៥ម ចែកជា ៨ បន្ទប់ (បន្ទប់ទល់ខ្នងគ្នា)
- សសរកន្ទោងកំពស់ ៣,២ម និងជើងរៀង ១,៧ម
- តួរោងព័ទ្ធដោយសំណាញ់ និងចែកខ័ណ្ឌជាបន្ទប់ៗ






- ខាងក្នុង មានធ្នើរ សម្រាប់ឱ្យមាន់ទំដេក
- តសំយ៉ាបរោងដាក់ទ្រុងកូន និងថែរក្សាកូនមាន់ដែលទើបញាស់

#### ខ. ទ្រុងថែរក្សាកូនមាន់ទើបញាស់










### ២. ស្នូកចំណី និង ស្នូកទឹក

- ត្រូវដាក់ស្នូកទឹក និងចំណី ឲ្យបានច្រើន គ្រប់គ្រាន់
- ស្នូកចំណី អាចច្នៃធ្វើពី ប៊ីដុង ឬ កានជ័រតូចធំ









### ៣. តើពូជមាន់ស្រុកបែបណា សមស្របសម្រាប់ការចិញ្ចឹម ?

- សុខភាពល្អ
- មាឌធំ ជើងលឿង
- មេនិងបាមិនជាប់ខ្សែស្រឡាយនឹងគ្នា
- បាពូកែជាន់មេ





- បា១ក្បាល ត្រូវដាក់បង្កាត់ជាមួយមេចំនួនពី ៦ ទៅ ៧ក្បាល

__*ចំណាំ:*__ មិនត្រូវទុកមេ និងបាចិញ្ចឹម ទាល់ចាស់មានអាយុលើសពី ៣ឆ្នាំ

## ៤. ការថែរក្សាកូនមាន់អាយុក្រោម ១ខែ (ទើបញាស់)



❶ ដាក់មេ និងកូនទើបញាស់ក្នុងទ្រុងមានក្រាលអង្កាម ឬ អាចម៌រណាជាមួយគ្នារហូតកូនមាន់អាយុ ១០ថ្ងៃទើបដកមេមាន់ចេញ

❷ បើត្រជាក់ខ្លាំង ឬ នៅពេលយប់ ត្រូវបន្ថែមកំដៅដោយបាំងជុំវិញទ្រុង ឬ ប្រើក្អមធ្យូងកំដៅ ឬដាក់អំពូលភ្លើងមូល (សីតុណ្ហភាព ពី ៣០ ទៅ ៣៥ អង្សារសេ)





❸ កូនមាន់អាយុបាន ១ខែ បញ្ចូលក្នុងទ្រុងបំប៉នមាន់សាច់ ដោយឲ្យដើរសេរី នៅក្នុងទ្រុងបំប៉ន

## ៥. ចំណីអាហារសម្រាប់មាន់

### ក. ចំណីកូនមាន់



- ត្រូវផ្តល់ចំណីដែលម៉ត់ ឬ ល្អិតៗ
- អាយុក្រោម ២១ថ្ងៃ ត្រូវផ្តល់ចំណីផ្សំស្រេចសុទ្ធ (ចំណីបាវ)
- អាយុលើ ២១ថ្ងៃ ត្រូវផ្តល់ចំណីផ្សំស្រេច (បាវ) លាយជាមួយកន្ទក់ ចុងអង្ករ និងបន្លែ ១០ ទៅ ២០% (ដើម្បីឲ្យស៊ីចំណី)

### ខ. ចំណីមេបា និង ចំណីមាន់បំប៉នយកសាច់

*តើត្រូវផ្សំចំណីដូចម្តេចដើម្បីឲ្យមាន់លូតលាស់ល្អ ហើយចំណាយថវិកា តិច ?*

- ផ្សំបញ្ចូលគ្នារវាងចំណីផ្សំស្រេច (បាវ)ចំនួន ៥០% និងចំណីដែលរកបាននៅក្នុងភូមិ ៥០% (ដូចជា ស្រូវ ចុងអង្ករ កន្ទក់ ពោត ត្រកួន ស្មៅ ផ្ទី ស្លឹកបាស កន្ធំថេត ចកបាយទា.... ។ល។)
- បន្ថែមក្នុងចំណី នូវម្សៅខ្យង ខ្ចៅ លៀស កន្ទុះស្វាបព្រា រាល់ថ្ងៃ
- ត្រូវផ្តល់ចំណីឲ្យមាន់ ចំនួនពី ២ ទៅ ៣ដង ក្នុង ១ថ្ងៃ





ច្របល់ចំណីចូលគ្នា

## ៦. ជីវៈសុវត្ថិភាព និង អនាម័យចិញ្ចឹមមាន់







- ផ្ទៃបាតទ្រុងស្ងួតជានិច្ច
- បាចកំបោរក្នុងទ្រុង រៀងរាល់មុនពេលដាក់មាន់ ១ អាទិត្យ
- ក្រាលអង្កាមនៅបាតទ្រុង
- ដាក់មាន់ជាក្រុមតាមអាយុប្រហែលគ្នាក្នុងបន្ទប់និមួយៗ
- សំអាតលាមករៀងរាល់ថ្ងៃ
- ផ្លាស់ប្តូរទឹករៀងរាល់ថ្ងៃ
- ដាក់ទឹកកំបោរថ្មនៅមាត់ច្រកចូលដើម្បីសំអាតបាតស្បែកជើងមុនចូលទ្រុងមាន់
- មាន់ងាប់ដោយជម្ងឺ ត្រូវដុត ឬ កប់ចោល

☠ ***ការប្រុងប្រយ័ត្ន***

*មិនត្រូវឲ្យឈ្មួញទិញមាន់ និងអ្នកដទៃ ចូលក្នុងទ្រុងមាន់ ឬ ក្នុងទីធ្លាទ្រុងចិញ្ចឹមមាន់ ឡើយ ។*

## ៧. វិធានការការពារជម្ងឺឆ្លង និង ទម្លាក់ព្រូនមាន់

ជម្ងឺមាន់កាចសាហាវ មានការរាលដាលខ្លាំង និងបណ្តាលឲ្យមាន់ងាប់ច្រើន ។ ជម្ងឺទាំងនេះមិនអាចព្យាបាលជាដាច់បានទេ ។ ដូច្នេះ ដើម្បីកុំឲ្យមាន់កើតជម្ងឺ អ្នកចិញ្ចឹមមាន់ ចាំបាច់ត្រូវ ៖

- ចាក់វ៉ាក់សាំងការពារ តាមពេលកំណត់ មុនពេលសត្វឈឺ
- មាន់ ១ក្បាលត្រូវចាក់វ៉ាក់សាំងយ៉ាងតិចណាស់ឲ្យបាន ៣មុខ (សម្រាប់បង្ការជម្ងឺ ៣មុខ គឺ ជម្ងឺ អុត ញ៉ូវកាស និង អាសន្នរោគ)
- ត្រូវចាក់វ៉ាក់សាំងការពារមាន់ទាំងអស់ និង ឱ្យបានទៀងទាត់
- មាន់មេ និងបា ត្រូវចាក់រំលឹកឡើងវិញរៀងរាល់ ៥ ទៅ ៦ខែម្តង (សម្រាប់ ជម្ងឺញ៉ូវកាស អាសន្នរោគ និង រលាកផ្លូវដង្ហើម)
- ត្រូវផ្តល់ថ្នាំទម្លាក់ព្រូនរៀងរាល់ ៣ខែម្តង

### *កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺឆ្លង និង ទម្លាក់ព្រូន*

អាយុ ១ ទៅ ៣ ថ្ងៃ → បន្តក់ វ៉ាក់សាំង ញ៉ូវកាស នៅលើភ្នែក ច្រមុះ



អាយុ ៧ ទៅ ១០ថ្ងៃ → វ៉ាក់សាំង អុត ជួសស្លាបរង



អាយុ២ខែ → ចាក់វ៉ាក់សាំង អាសន្នរោគ នៅសាច់ដុំទ្រូង



អាយុ ២ខែកន្លះ → ទម្លាក់ព្រូន (លាយចំណី)



***<u>សម្រាប់ព័ត៌មានបច្ចេកទេសលំអិតបន្ថែម សូមអាន</u>***

*សៀវភៅ បច្ចេកទេសចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ ឬ*

http://telecentercambodia.org/link/download/Chicken_Training_Manual.pdf

រៀបចំដោយ: លោក ស៊ិន ប៉ោ

អ្នកជំនាញផ្នែកបសុសត្វ របស់គម្រោង TSTD

porsinn@gmail.com